# មេរៀនទី ១២: ព្រះយេស៊ូវបង្រៀនអំពីរទ្វាន់

## លូកា:១៧-២៦

**គោលបំណង៖** ព្រះយេស៊ូវចង់ឲ្យយើងស្វែងរកនគរព្រះជាមុនសិន។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៦:៣៣** *"ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

តើទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះមានឥទ្ធិពលបែបណាចំពោះអ្នក? នៅក្នុងគ្រាលំបាកតើទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះមានលក្ខណៈយ៉ាងណាដែរ? ចូរអរព្រះគុណចំពោះពេលវេលាដ៏ល្អ ប៉ុន្តែក៏ត្រូវដឹងគុណចំពោះគ្រាដ៏លំបាកដែលអាចទាញយើងឲ្យខិតទៅជិតព្រះអម្ចាស់ផងដែរ។ ថ្ងៃនេះ សូមអធិស្ឋានសម្រាប់នរណាម្នាក់ដែលកំពុងតែជួបការលំបាក ថាការលំបាកនោះនឹងជួយគាត់ឱ្យកាន់តែមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះអម្ចាស់បបន្ថែមទៀត។

**ចំរៀង៖** ១. បើទ្រង់គង់ជាមួយ ២. ខ្ញុំនឹងទុកចិត្តទ្រង់ ៣. ព្រះយេស៊ូវស្រឡាញ់កុមារណាស់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត « តើអ្នកមើលឃើញអ្វី? »**

សូមបោះពុម្ពរូបភាពដែលនៅទំព័រខាងក្រោមបង្ហាញដល់កុមារ។ អ្នកអាចមើលឃើញរូបភាពទាំងនេះមានរូបពីរផ្សេងគ្នា។ សួរកុមារថាតើពួកគេមើលឃើញអ្វី?



សត្វទា ឬទន្សាយ?



ថូផ្កា ឬមុខមនុស្ស២នាក់?



ក្មេងស្រី ឬស្ត្រីចំណាស់?

ពន្យល់កុមារថាអ្វីដែលយើងមើលឃើញនៅក្នុងពិភពលោកនេះ អាចនឹងមិនមែនជាអ្វីដែលយើងកំពុងតែឃើញវានោះក៏ថាបាន។ អ្វីដែលមនុស្សគិតថា ជារឿងសំខាន់អាចនឹងមិនមែនជារឿងសំខាន់នៅក្នុងព្រះនេត្ររបស់ព្រះ។

## ៤. ការណែនាំមេរៀន

តើអ្នកគិតថាអ្វីនឹងធ្វើឱ្យមនុស្សសប្បាយចិត្ត? (មិត្តភក្តិច្រើន លុយ ផ្ទះស្អាត ប្រដាប់ក្មេងលេង ខោអាវ ទូរស័ព្ទថ្មី) ប៉ុន្តែបើខ្ញុំទិញទូរស័ព្ទថ្មីឱ្យអ្នកថ្ងៃនេះ តើសុភមង្គលអ្នកនឹងនៅបានយូរប៉ុណ្ណា? តើអ្នកនឹងសប្បាយចិត្តជារៀងរហូតទេ? ទេ អ្វីៗក្នុងលោកនេះមិនអាចធ្វើឲ្យយើងសប្បាយចិត្តជារៀងរហូតនោះទេ។ យើងនឹងសប្បាយចិត្តក្នុងរយៈពេលខ្លី ប៉ុន្តែយើងនឹងចង់បានរបស់ច្រើនទៀត និងរបស់ល្អជាងមុនៗទៅទៀត។ ព្រះមិនចង់ឱ្យយើងរស់នៅដើម្បីតែរបស់របរនៅក្នុងលោកីយ៍នេះប៉ុណ្ណោះទេ។ ទ្រង់ចង់បង្រៀនយើងថាមានអ្វីផ្សេងៗជាច្រើនទៀតដែលសំខាន់ជាងការដែលយើងគ្រាន់តែរស់នៅ ដើម្បីចង់បានតែរបស់នៅលោកីយ៍នេះទៅទៀត។ សូមយើងរៀនអំពីអ្វីដែលអ្វីនៅក្នុងរឿងព្រះគម្ពីរថ្ងៃនេះចង់ប្រាប់យើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ ព្រះយេស៊ូវបានមានបន្ទូលអំពីអ្វីៗទាំងអស់មិនមែនតែងតែកើតឡើង ដោយសមហេតុផលរហូតនោះទេ។ ព្រះអង្គមានបន្ទូលថា **លូកា ៦:២០-២២** “មានពរហើយអ្នករាល់គ្នាដែលក្រអើយ ដ្បិតនគរព្រះជារបស់ផងអ្នករាល់គ្នា។ មានពរហើយ អ្នករាល់គ្នាដែលឃ្លានឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹងបានឆ្អែត មានពរហើយអ្នករាល់គ្នាដែលយំឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹងបានសើចវិញ។ មានពរហើយកាលណាមនុស្សនឹងស្អប់អ្នករាល់គ្នាព្រមទាំងកាត់កាលត្មះតិះដៀល ហើយចោលឈ្មោះអ្នករាល់គ្នាចេញទុកដូចជាអាក្រក់ដោយព្រោះកូនមនុស្ស។”

ព្រះអង្គក៏មានបន្ទូលដែរថា **លូកា ៦:២៤-២៦** “តែវេទនាដល់អ្នករាល់គ្នាជាអ្នកមាន ដ្បិតអ្នករាល់គ្នាកំពុងតែមានសេចក្តីកំសាន្តចិត្តក្នុងសម័យនេះ។ វេទនាដល់អ្នករាល់គ្នាដែលឆ្អែត ដ្បិតនឹងត្រូវឃ្លានវិញ វេទនាដល់អ្នករាល់គ្នាដែលសើចក្នុងជាន់ឥឡូវនេះ ដ្បិតនឹងកើតទុក្ខព្រួយហើយយំសោកវិញ។ វេទនាដល់អ្នករាល់គ្នាកាលណាមនុស្សទាំងអស់និយាយល្អពីអ្នករាល់គ្នា ពីព្រោះកាលពីដើមពួកឰយុកោបានប្រព្រឹត្តនឹងពួកហោរាក្លែងក្លាយយ៉ាងដូច្នោះដែរ។”

ព្រះមានបន្ទូលថា មានពរហើយ អ្នករាល់គ្នាដែលក្រអើយ ដ្បិតនគរព្រះជារបស់ផងអ្នករាល់គ្នា។ ទ្រង់ក៏មានបន្ទូលថា តែវេទនាដល់អ្នករាល់គ្នា ជាអ្នកមើលទៅដូចជាមានគ្រប់យ៉ាងដែលពួកគេចង់បាន។ ទ្រង់មានបន្ទូលថាអ្នកដែលមានមិត្តភក្តិច្រើន ហើយអ្នកទាំងនោះអាចនឹងមិនមែនជាមិត្តភក្តិជាមួយនឹងព្រះអង្គទេ។ ទ្រង់មានបន្ទូលថាអស់អ្នកដែលមើលទៅមាន អាចនឹងក្រខ្លាំងណាស់ពីព្រោះពួកគេមិនស្គាល់ព្រះទេ។

ព្រះយេស៊ូវចង់ឲ្យមនុស្សបានដឹងថា ពួកគេត្រូវប្រុងប្រយ័ត្ននៅពេលដែលពួកគេសម្រេចចិត្តចង់បាននូវ របស់អ្វីមួយសម្រាប់ជីវិតរបស់ពួកគេ។ ប្រសិនបើអ្នកជ្រើសរើសដើរតាមព្រះយេស៊ូវ អ្នកអាចប្រឈមមុខនឹងការបៀតបៀន ទុក្ខលំបាក ការរើសអើង និងការមិនចូលចិត្តពីអ្នកដ៏ទៃ ប៉ុន្តែអ្នកត្រូវចាំថា ព្រះតែងតែនៅជាមួយអ្នក។ ព្រះតែងតែឆ្លើយតបនឹងការអធិស្ឋានរបស់អ្នក ពេលយើងទូលសូមដល់ទ្រង់។ ព្រះសន្យាថានឹងប្រទានពរដល់យើង យើងនឹងទទួលបានរង្វាន់ទាំងនៅលើផែនដី និងនៅនគរស្ថានសួគ៌ផងដែរ។

**៦. សំនួរពិភាក្សា**

១. តើក្នុងព្រះគម្ពីរនិយាយថាយើងគួរតែស្វែងរកអ្វីក្នុងជីវិតយើង? *នគររបស់ព្រះ*

២. តើប្អូនធ្វើអ្វីដើម្បីឲ្យបានរង្វាន់ពីព្រះ ?*ដើរតាមផ្លូវរបស់ព្រះ*

៣.តើអ្នកអាចស្វែងរកនគររបស់ព្រះនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា? *ដោយការជ្រើសរើសផ្លូវ របស់ព្រះក្នុងការរស់នៅ និងអនុវត្តន៍តាមព្រះបន្ទូលរបស់ទ្រង់*

**៧. ល្បែងកំសាន្ត** «ស្វែងរកកំណប់»

**សម្ភារៈដែលត្រូវការ៖** ស្ករគ្រាប់ និងព្រះគម្ពីរ ៣ក្បាល

១. លាក់ស្ករគ្រាប់ និងព្រះគម្ពីរនៅក្នុងថ្នាក់រៀន

២. ឲ្យកុមារស្វែងរកអ្វីដែលគិតថាជាកំណប់ពិតប្រាកដ

៣. កុមារដែលយកព្រះគម្ពីរមកជាអ្នកឈ្នះ។ សូមឲ្យស្ករគ្រាប់ច្រើនទៅកុមារនោះ។

៤. ពន្យល់កុមារថាពេលដែលយើងស្វែងរកនគរព្រះជាមុន (ផ្លូវរបស់ព្រះ) យើងនឹងបានព្រះពរច្រើនជាងពេលដែលយើងស្វែងរកផ្លូវរបស់លោកីយ៍។

**៨. ខគម្ពីរចងចាំ** ម៉ាថាយ ៦:៣៣

**៩. ហត្ថកម្ម** ផាត់ពណ៌លើរូបភាព - ម៉ាថាយ ៦:៣៣

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# រូបភាពទី១- សត្វទា ឬទន្សាយ?



# រូបភាពទី២- ថូផ្កា ឬមុខមនុស្ស២?



រូបភាពទី៣- ក្មេងស្រី ឬស្ត្រីចំណាស់?





# ម៉ាថាយ ៦៖៣៣

ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃ
ព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ
នឹងបានប្រទានមកអ្នករាល់គ្នា
ថែមទៀតផង